# ស្រុកថ្មគោល៖ កុមារក្រីក្រទទួលបានសំបុត្រអត្រានុកូលដ្ឋានកំណើត

កិច្ចប្រជុំសាមញ្ញរបស់គ.ក.ស.ក



1. តំណាង **គ.ក.ន.ក** នៅតាមបណ្តាឃុំមួយចំនួន បានរាយការណ៍អំពីបញ្ហាកុមារជាច្រើនមិនទាន់មានសំបុត្រកំណើតនៅឡើយ។
2. **គ.ក.ស.ក** បានពិភាក្សានិងសម្រេចចិត្តផ្តល់យោបល់ដល់ក្រុមប្រឹក្សាស្រុក អំពីបញ្ហានេះដើម្បីពិចារណា។
3. **គ.ក.ស.ក** បានស្នើឲ្យ **គ.ក.ន.ក** ចុះស្រង់និងផ្តល់ទិន្នន័យឲ្យបានច្បាស់លាស់ នូវចំនួនគ្រួសារដែលកុមារគ្មានសំបុត្រកំណើត។
4. ជាលទ្ធផល កុមារចំនួន១៥៧នាក់/៧៧ស្រីត្រូវបានរកឃើញ ដែលភាគច្រើនមកពីគ្រួសារក្រីក្រ លែងលះ និងចំណាកស្រុក។

16/12/2020

កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា



5. នៅក្នុងកិច្ចប្រជុំលើកទី២០ ប្រធានក្រុមប្រឹក្សាស្រុក បានលើកឡើងពីសារសំខាន់នៃសំបុត្រកំណើត ដើម្បីទទួលបាននូវសេវាសាធារណៈជាច្រើនដូចជាសេវាអប់រំជាដើម។
6. ក្រុមប្រឹក្សាស្រុក បានអនុម័តគាំទ្រដោយសម្លេង១៨/១៨ ដើម្បីដោះស្រាយបញ្ហានេះជូនប្រជាពលរដ្ឋ។
7. គណៈអភិបាលស្រុកត្រូវបានប្រគល់ភារកិច្ចក្នុងការបង្កើតក្រុមការងារ និងដោះស្រាយ។

4/02/202

កិច្ចប្រជុំរបស់គណៈអភិបាល



8. បង្កើតក្រុមការងារមានសមាជិកមកពីរដ្ឋបាលឃុំ និងស្រុក។
9. ក្រុមការងារបានផ្ទៀងផ្ទាត់ទិន្នន័យដើមគ្រា និងវិភាគអ្នកពាក់ព័ន្ធសំខាន់ៗដូចជា មន្ត្រីអត្រានុកូលដ្ឋានឃុំ ស្រុក មេភូមិ នាយកសាលាបឋមសិក្សា និងប្រធានមណ្ឌលសុខភាពជាដើម។
10. ក្រុមការងារ បានសិក្សានិងរៀបចំសំណើគម្រោងដាក់ជូនក្រុមប្រឹក្សាអនុម័ត និងបន្ទាប់មកបានដាក់ស្នើទៅកម្មវិធីដា (DAR) ដើម្បីកៀរគរធនធាន។

5/4/2021

ដំណើរការអនុវត្ត



11. ក្រុមការងារបានប្រជុំពិភាក្សានិងសម្រេចបញ្ជាក់អត្រានុកូលដ្ឋានកំណើតស្របតាមនីតិវិធីណែនាំរបស់ថ្នាក់ជាតិ និងធ្វើបច្ចុប្បន្នភាពលទ្ធផលនិងបញ្ហាប្រឈមនានាជូនអង្គប្រជុំឲ្យបានទៀងទាត់។
12. បើកវគ្គរំឭកឡើងវិញស្តីពីអត្រានុកូលដ្ឋានកំណើតដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ និងស្រុក បណ្តុះបណ្តាលដោយខេត្ត។
13. បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ ជាពិសេសក្នុងចំណោមគ្រួសារក្រីក្រ ចំណាកស្រុកនិងលែងលះ តាមរយៈការផ្សព្វផ្សាយចល័តទូទាំងស្រុក និងចែកខិតប័ណ្ណចំនួន៣០០០សន្លឹក។
14. តម្លើងផ្ទាំងប៉ាណូផ្សព្វផ្សាយធំៗចំនួន២ផ្ទាំងនៅមុខសាលាឃុំនិងស្រុក ដើម្បីអប់រំប្រជាពលរដ្ឋបន្ថែមអំពីរបៀប និងទីកន្លែងដែលធ្វើឬបញ្ជាក់សំបុត្រកំណើត។
15. មេភូមិបានចុះទាក់ទងផ្ទាល់តាមគ្រួសារនីមួយៗដែលមានកុមារគ្មានសំបុត្រកំណើតដើម្បីឲ្យមកធ្វើសំបុត្របញ្ជាក់កំណើតឲ្យកូនឬចៅរបស់ពួកគាត់នៅសាលាឃុំដែលពួកគាត់កំពុងរស់នៅ។

12/7-30/11/21

ការផ្សព្វផ្សាយ



21/12/2021

16. ក្រោយពីអនុវត្តគម្រោងប្រកបដោយជោគជ័យកុមារសរុប១៥៧នាក់ស្រី៧៧នាក់បានទទួលសំបុត្របញ្ជាក់កំណើតគ្រប់ៗគ្នា។
17. ក្រុមការងារបានសរសេររបាយការណ៍សម្រាប់ចែករំលែកដល់អ្នកពាក់ព័ន្ធនិងតម្កល់ទុកជាឯកសារ។ លើសពីនេះ ស្រុកបានផ្សព្វផ្សាយករណីជោគជ័យនេះ តាមទំព័រហ្វេសប៊ុករបស់រដ្ឋបាលស្រុកថ្មគោល។

# ស្រុករតនមណ្ឌល៖ កិច្ចសម្របសម្រួលជួយកុមាររស់នៅក្នុងគ្រួសារមានហានិភ័យខ្ពស់

**សាវតារ៖** កុមារ២នាក់បងប្អូន(កុមារីអាយុ១៣ឆ្នាំ និងកុមារាអាយុ១១ឆ្នាំ) រស់នៅក្នុងគ្រួសារក្រីក្រនិងនៅដាច់ឆ្ងាយពីគេ។ កុមារទាំងពីរនៅតែក្នុងផ្ទះ២៤ម៉ោង មិនចេញទៅលេងខាងក្រៅជាមួយកុមារផ្សេងទៀត ហើយក៏មិនទៅរៀនដែរ។ ឪពុកពួកគេបានចេញទៅធ្វើការដើម្បីផ្គត់ផ្គង់គ្រួសារ ប៉ុន្តែជីវភាពពួកគេនៅតែបានព្រឹកខ្វះល្ងាច ខណៈដែលម្តាយរបស់ពួកគេជាមនុស្សញៀនស្រា។ ដោយសារតែអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងគ.ក.ស.ក បានជួយឧបត្ថម្ភស្បៀងអាហារ និងសម្លៀកបំពាក់ជាប្រចាំចាប់តាំងពីឆ្នាំ២០១៦រហូតមក ដែលជាហេតុធ្វើឲ្យម្តាយពួកគេមិនព្រមបញ្ជូនពួកគេទាំង២ទៅរៀន ឬទៅរស់នៅកន្លែងផ្សេងរហូតទាល់តែគាត់ស្លាប់នៅក្នុងឆ្នាំ២០២០។ កុមារទាំង២ស្ទើរតែមិនចេះនិយាយស្តី មិនដែលបានចុះឈ្មោះចូលរៀន និងមិនអាចឆ្លើយតបទៅនឹងសំណួរសាមញ្ញដោយសារខ្វះការទំនាក់ទំនងក្នុងសង្គម និងមិនមានការយកចិត្តទុកដាក់ជាច្រើនឆ្នាំ។ ការមិនយកចិត្តទុកដាក់ពីក្រុមគ្រួសារ អ្នកជិតខាង និងអ្នកក្រៅនាំឲ្យមានហានិភ័យដ៏ខ្ពស់នៃការរំលោភបំពាន ដូច្នេះទើបអាជ្ញាធរយកចិត្តទុកដាក់ជាប្រចាំ។

| 2016 | 2018 | 2020 | 2020 |
|---|---|---|---|
| **គ.ក.ស.ក** បានអន្តរាគមន៍ដល់គ្រួសារនេះ ដោយផ្តល់ស្បៀងអាហារតាមរយៈអង្គការមនុស្សធម៌ក្នុងស្រុក។ | គាំទ្រ និងពិគ្រោះយោបល់ជាមួយគ្រួសារជាប្រចាំ ដោយសារតែម្តាយញៀនស្រា និងកូនៗមិនបានចូលរៀន។ | ម្តាយពួកគេបានស្លាប់ ហើយពួកគេបានរស់នៅតែលតោលក្នុងផ្ទះដាច់ស្រយាល ដែលអាចប្រឈមនឹងគ្រោះថ្នាក់ មិនបានរៀនសូត្រ និងអាហារខ្វះជីវជាតិ។ | ឪពុកបានឯកភាពបញ្ជូនកុមារទាំង២ទៅកាន់ជម្រកសុវត្ថិភាពនៅមណ្ឌលភូមិកុមារ(SOS)នៅខេត្តបាត់ដំបង។ |

អំឡុងពេលកិច្ចប្រជុំប្រចាំខែកញ្ញា ២០២០ **គ.ក.ស.ក** បានរាយការណ៍ថា មេភូមិស្តៅបានលើកឡើងពីបញ្ហា នៃស្ថានភាពកុមារពីរនាក់បងប្អូននៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ដោយសង្ឃឹមថាបានគាំទ្រផ្នែកសេវាសង្គម។ ក្រៅពីការឧបត្ថម្ភរយៈពេលខ្លី **គ.ក.ន.ក** បានពិភាក្សាអំពីការដោះស្រាយបញ្ហានេះក្នុងរយៈពេលវែងដោយសារកន្លងមក អន្តរាគមន៍ រយៈពេលខ្លីតាំងពីឆ្នាំ២០១៦ មិនបានកែលម្អស្ថានភាពកុមារឡើយ។




កាលពីខែវិច្ឆិកា ឆ្នាំ២០២០ ប្រធាន**គ.ក.ស.ក** ស្រុកបានរាយការណ៍អំពីលទ្ធផលនៃការដោះស្រាយបញ្ហាកុមារប្រឈមនឹងហានិភ័យខ្ពស់ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុកដើម្បីចែករំលែកព័ត៌មានដល់អ្នកពាក់ព័ន្ធដែលបានចូលរួមប្រជុំផងដែរ។

**គ.ក.ន.ក** និងមេឃុំ បានសម្របសម្រួលឲ្យមានការគាំទ្រពីអង្គការឧបត្ថម្ភគ្រួសារកម្ពុជា ក្នុងការបញ្ជូនកុមារទៅកាន់ជម្រកសុវត្ថិភាពបណ្តោះអាសន្ននៅខែកញ្ញាឆ្នាំ២០២០ បន្ទាប់ពីមានការព្រមព្រៀងពីឪពុកកុមារ។ ២ខែក្រោយមក កុមារទាំងពីរនាក់ត្រូវបានបញ្ជូនទៅរស់នៅមណ្ឌលភូមិកុមារ អេសអូអេស ក្នុងខេត្តបាត់ដំបងក្រោមកិច្ចសម្របសម្រួលយ៉ាងសកម្មពីមេឃុំ **គ.ក.ន.ក** និងអង្គការឧបត្ថម្ភគ្រួសារកម្ពុជា។ **គ.ក.ស.ក** បានតាមដានជាប្រចាំ និងរាយការណ៍អំពីការផ្លាស់ប្តូរចរិតរបស់កុមារ ដោយចេះលេងសើច ចេះនិយាយច្រើន និងមានភាពសកម្មជាងមុន ហើយពួកគេកំពុងរៀននៅថ្នាក់ទី២ជាមួយគ្នា។

រដ្ឋបាលស្រុករតនមណ្ឌល បានចងក្រងនឹងផ្សព្វផ្សាយអំពីអត្ថបទខ្លីមួយ ស្តីពីការជួយអន្តរាគមន៍ដល់កុមារពីរនាក់បងប្អូន ដើម្បីចែករំលែកបទពិសោធន៍ដែលទទួលបានជោគជ័យនេះ ដល់ស្រុកផ្សេងៗតាមរយៈទំព័រហ្វេសប៊ុករបស់រដ្ឋបាលស្រុក នៅខែសីហាឆ្នាំ២០២០។

# កុមារីអនាថានៅស្រុកកំរៀងបាននៅរស់នៅកន្លែងមានសុវត្ថិភាព

## ការកំណត់បញ្ហា ដោយ គ.ក.ស.ក

មេភូមិ បានរាយការណ៍ពីកុមារីអនាថាម្នាក់ ត្រូវបានគេយកទៅចិញ្ចឹម ដោយមិនបានជូនដំណឹង ដល់អាជ្ញាធរ ឬមិនបានអនុវត្តតាមនីតិវិធីច្បាប់ ហើយមានកុមារផ្សេងទៀត ក៏រស់ជាមួយអាណាព្យាបាលរបស់កុមារីនេះផងដែរ។ គាត់បានរាយការណ៍ទៅ គ.ក.ន.ក ឃុំ ដើម្បីពិនិត្យស្ថានភាពឲ្យបានច្បាស់លាស់។ បន្ទាប់មក គ.ក.ន.ក ក៏បានពិភាក្សា និងរាយការណ៍ពីបញ្ហានេះ ទៅ គ.ក.ស.ក ដើម្បីចាត់វិធានការបន្ត។

29/8/2020

## កិច្ចប្រជុំប្រចាំខែ របស់ គ.ក.ស.ក

- គ.ក.ស.កស្រុកបាន បញ្ចូលបញ្ហានេះទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំប្រចាំខែរបស់ខ្លួន
- គ.ក.ស.ក បានប្រមូលព័ត៌មានពាក់ព័ន្ធបន្ថែមទៀតនិងបានពិភាក្សារកវិធីសាស្ត្រដោះស្រាយបញ្ហានេះ
- បន្ទាប់មក គ.ក.ស.ក បានរៀបចំរបាយការណ៍ និងអនុសាសន៍សម្រាប់ផ្តល់ជូនក្រុមប្រឹក្សាស្រុក ក្នុងកិច្ចប្រជុំប្រចាំខែ របស់ក្រុមប្រឹក្សាស្រុក។

02-03/9/2020

## កិច្ចប្រជុំប្រចាំខែរបស់ ក្រុមប្រឹក្សាស្រុក

- ប្រធានគ.ក.ស.កបានផ្តល់យោបល់ដល់ក្រុមប្រឹក្សាស្រុកអំពីបញ្ហាកុមារីអនាថា
- ក្រុមប្រឹក្សាស្រុកបានពិភាក្សាពីបញ្ហានេះជាមួយអ្នកចូលរួម ជាពិសេសមានគណៈអភិបាលស្រុក នគរបាលស្រុក នគរបាលឃុំ និងការិ. សង្គមកិច្ចស្រុក
- ក្រុមប្រឹក្សាបានសម្រេចចិត្តដោះស្រាយបញ្ហានេះ និងចាត់ឲ្យគណៈអភិបាលជាអ្នកទទួលខុសត្រូវ។
- ទន្ទឹមនឹងនោះ គណៈអភិបាលបានចាត់តាំងមន្ត្រី ១ក្រុមដើម្បីដោះស្រាយបញ្ហានេះនិងរាយការណ៍ជូនគណៈអភិបាល។

04/9/2020

## កិច្ចប្រជុំ គណៈអភិបាល

គណៈអភិបាលមិនបានរៀបចំកិច្ចប្រជុំដាច់ដោយឡែក ដើម្បីចាត់តាំងក្រុមការងារនោះទេ ដោយសារមន្ត្រីដែលពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហានេះត្រូវបានចាត់តាំងក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សារួចហើយ។

## អនុវត្តសកម្មភាព

- កិច្ចសហការល្អរវាងស្រុក នគរបាលឃុំ/ស្រុក និងឃុំ
- ប្រធានគកសក ក្រុមប្រឹក្សាឃុំបានចុះសួរសុខទុក្ខកុមារីដល់ផ្ទះដែលនាងបានរស់នៅជាមួយ
- ស៊ើបអង្កេតគ្រួសារអាណាព្យាបាលកុមារីដោយសង្ស័យពាក់ព័ន្ធនឹងការជួញដូរកុមារ
- បញ្ជូនកុមារទៅស្នាក់នៅមណ្ឌលសំចតនៅប៉ៃលិន
- រដ្ឋបាលស្រុកបានទំនាក់ទំនង SOS ភូមិកុមារកម្ពុជា ទីបំផុតកុមារីនេះត្រូវបានញ្ជូនទៅរស់នៅនិងទទួលបានការអប់រំនិងថែទាំនៅមណ្ឌលSOS ដោយមានម្តាយមីងរបស់នាងបានជូនដំណើរដល់ទីនោះផងដែរ ដើម្បីបានស្គាល់កន្លែងដែលកុមារីរស់នៅ។

7/9-02/10/2020

## ការផ្សព្វផ្សាយ

- បន្ទាប់ពីបានដោះស្រាយបញ្ហានេះដោយជោគជ័យ ក្រុមការងារថ្នាក់ស្រុកបានសរសេររបាយការណ៍និងចែករំលែកដល់អ្នកពាក់ព័ន្ធ
- ស្រុកក៏បានសរសេរអត្ថបទអំពីការដោះស្រាយបញ្ហានេះ និងផ្សព្វផ្សាយតាមទំព័រហ្វេសប៊ុករបស់រដ្ឋបាលស្រុកដើម្បីចែករំលែកបទពិសោធន៍បន្ថែមទៀត។

8/12/2020